# គ្រោះធម្មជាតិជាបញ្ហាសម្រាប់ការអភិវឌ្ឍ ឯការអភិវឌ្ឍ ក៏ជះផលអាក្រក់បង្កឱ្យប្រឈមនឹងគ្រោះធម្មជាតិ

របាយការណ៍ស្ដីអំពី "ការកាត់បន្ថយការប្រឈមមុខនឹងគ្រោះធម្មជាតិ បញ្ហាប្រឈមក្នុងការអភិវឌ្ឍ" និងត្រូវប្រកាសផ្សាយដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងកិច្ចប្រជុំយុទ្ធសាស្ត្រអន្តរជាតិសម្រាប់កាត់បន្ថយគ្រោះធម្មជាតិនៅអាស៊ី ដែលនឹងរៀបចំធ្វើឡើងនៅទីក្រុងសៀមរាប ចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ ខាងមុខនេះ។

នៅក្នុងសន្និសីទកាសែតមួយកាលពីថ្ងៃទី០៣ខែកុម្ភៈ ស្ដីអំពីសារៈសំខាន់ៗសម្រាប់តំបន់អាស៊ី ទាក់ទងនឹងការកាត់បន្ថយភាពងាយទទួលគ្រោះថ្នាក់ធម្មជាតិ និងបញ្ហាប្រឈមមុខក្នុងការអភិវឌ្ឍនេះ លោកស្រី អាមីកា ហាក់ នាយកនៃការិយាល័យការពារនិងស្ដារឡើងវិញគ្រោះមហន្តរាយ បានមានប្រសាសន៍ឱ្យដឹងថា បញ្ហាគ្រោះធម្មជាតិបានបង្កឱ្យមានការខូចខាតធំធំលើការអភិវឌ្ឍ ហើយទន្ទឹមគ្នានោះដែរ ដំណើរនៃការអភិវឌ្ឍក៏បានជះឥទ្ធិពលអាក្រក់នាំឱ្យមានការប្រឈមមុខនឹងគ្រោះធម្មជាតិផងដែរ។

លោកស្រី អាមីកា ហាក់ បានសង្កត់ធ្ងន់ថា ការកើតមាននូវគ្រោះទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួតជាញឹកញាប់ និង ធ្ងន់ធ្ងរឡើងៗនៅអាស៊ី គឺវាបានធ្វើឱ្យប៉ះពាល់យ៉ាងច្រើនតែលើសហគមន៍ក្រីក្រ ដែលកំពុងតែធ្វើឱ្យខូចនូវដំណើរការ និងគោលដៅអភិវឌ្ឍប្រចាំសហស្សវត្សនេះតែម្ដង។ តាមរយៈការសិក្សាបានបង្ហាញថា បណ្ដាប្រទេសនៅអាស៊ីកំពុងតែទទួលរងនូវការបាត់បង់ផ្នែកសេដ្ឋកិច្ចយ៉ាងច្រើនដោយសារតែគ្រោះធម្មជាតិ ក្នុងនោះទឹកជំនន់ គឺជាគ្រោះធម្មជាតិដែលតែងតែកើតមានញឹកញាប់ជាងគេនៅក្នុងតំបន់ ហើយការអភិវឌ្ឍធនធានមនុស្សក៏ប្រហែលជាទទួលរងនូវការខូចខាតច្រើនជាងទិន្នន័យដែលបានបង្ហាញដែរ។

តាមការអះអាងបន្ថែមរបស់លោកស្រី អាមីកា ហាក់ បានបង្ហាញថាគ្រោះធម្មជាតិបណ្ដាលមកពីការបំផ្លាញធនធានធម្មជាតិទូទៅនៅលើផែនដីនេះតែម្ដងដែលតម្រូវឱ្យរាជរដ្ឋាភិបាលនៃប្រទេសនីមួយៗជាពិសេសក្រសួងកសិកម្ម ធនធានទឹក បរិស្ថាននគរូបនីយកម្មនិងសំណង់ ។ល។ ត្រូវតែយកចិត្តទុកដាក់លើបានការថែរក្សាឡើងវិញជាបន្ទាន់។

ជាទូទៅ ១១ភាគរយនៃប្រជាពលរដ្ឋកម្ពុជាបានទទួលផលប៉ះពាល់ពីគ្រោះធម្មជាតិ ហើយក្នុងនេះចំនួនអ្នកស្លាប់មាន ៤,០៨ភាគរយ ដែលបញ្ហានេះគេច្រើនចាត់ទុកថា នេះជាករណីមួយពិសេសដែលបានដោះស្រាយដោយការផ្ដល់ជំនួយសប្បុរសធម៌ទៅវិញ។ លោកស្រី អាមីកា ហាក់ បានលើកឡើងថា អ្វីដែលលើកឡើងក្នុងរបាយការណ៍ខាងលើនេះត្រូវផ្ដោតទៅលើការដោះស្រាយដោយការរំពឹងទុក និងព្យាករណ៍ជាមុនចំពោះករណីគ្រោះថ្នាក់ធម្មជាតិ ហើយដែលត្រូវទប់ស្កាត់វាជាមុនដោយវិធីផ្សេងៗវិញផងដែរ។

តាមរបាយការណ៍បានបង្ហាញនូវទិន្នន័យ ដែលបញ្ជាក់នូវកត្តាអភិវឌ្ឍនានាដែលនាំមកនូវគ្រោះថ្នាក់ធម្មជាតិនេះផងដែរ និងបានបង្ហាញនូវកាលវេលានៃការកាត់បន្ថយ ឬការធ្វើអោយគ្រោះថ្នាក់កាន់តែកើនឡើងគឺអាស្រ័យលើការជ្រើសរើសនូវគោលនយោបាយសមស្របនោះតែម្ដង។

Kampuchea Thmey Daily
Date: 05 Feb. 2004
Vol: 3 , Issue: 346